**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ: ១០៦ ......សហវ.ប្រក.

*រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨*

# ប្រកាស
# ស្តីពី
# សន្និធិគយបណ្តោះអាសន្ន

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែល ប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខនស / រកម / ០៧០៧ / ០១៧ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## <u>សម្រេច</u>

**ប្រការ ១.-**

បង្កើតសន្និធិគយបណ្តោះអាសន្នលើទំនិញនាំចូល និងនាំចេញ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់គយ នៅតាមទីកន្លែងដែលមានការអនុញ្ញាតពីគយ ដើម្បីបំពេញទម្រង់ការគយ ដោយអនុលោមតាមបញ្ញត្តិមាត្រា ២៣ នៃច្បាប់ស្តីពីគយ ។ ទីកន្លែងសន្និធិគយបណ្តោះអាសន្នរួមមាន បណ្តាគណ្ឋាគារ ឃ្លាំង និងទីធ្លាដែលទទួល បញ្ចេញទំនិញពីគយដែលស្ថិតក្រោមការគ្រប់គ្រងរបស់គយ ។

**ប្រការ ២.-**

លក្ខខណ្ឌនានាពាក់ព័ន្ធនឹងអាជ្ញាប័ណ្ណសម្រាប់ប្រតិបត្តិការទីកន្លែងសន្និធិគយបណ្តោះអាសន្ន មានដូចខាងក្រោម ៖

១. អាជ្ញាប័ណ្ណសម្រាប់ប្រតិបត្តិការទីកន្លែងសន្និធិគយបណ្តោះអាសន្ន ត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ អាជ្ញាប័ណ្ណនេះនឹងកំណត់នូវលក្ខខណ្ឌសម្រាប់ម្ចាស់កម្មសិទ្ធ និងប្រតិបត្តិករ រាប់បញ្ចូលទាំងទីតាំងសំណង់ គម្រោងអាគារ កម្រិតនិមុត្តិជានា ព្រមទាំងនីតិវិធីសម្រាប់ចាត់ចែងគ្រប់គ្រងនិងត្រួតពិនិត្យទំនិញ ។

២. បុគ្គលដែលមានបំណងស្នើសុំអាជ្ញាប័ណ្ណ ត្រូវដាក់ពាក្យស្នើសុំទៅនាយកទីចាត់ការគយ និងរដ្ឋាករ តាមទម្រង់ដែលបានកំណត់ដោយភ្ជាប់ទៅជាមួយនូវប្លង់នៃសំណង់ និងទីតាំងនៃទីកន្លែងសន្និធិគយបណ្តោះអាសន្ន ដែលស្នើសុំ ។

៣. អាជ្ញាប័ណ្ណអាចនឹងត្រូវចេញជូនបានប្រសិនបើ ៖

- អ្នកស្នើសុំមានលក្ខណៈសម្បត្តិល្អ
- អ្នកស្នើសុំមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ សម្រាប់ផ្គត់ផ្គង់ដល់ការសាងសង់ទីកន្លែង បំពាក់បរិក្ខារ ដល់បុគ្គលិក និងសេវាកម្មចាំបាច់នានា នៃកិច្ចប្រតិបត្តិការ
- ទីតាំងស្នើសុំសម្រាប់សាងសង់ទីកន្លែងសន្និធិគយបណ្តោះអាសន្នត្រូវស្ថិតក្នុងចម្ងាយសមស្របមួយពីផ្លូវគមនាគមន៍សំខាន់ និងពីការិយាល័យគយ និងត្រូវមានទំហំផ្ទៃក្រឡាគ្រប់គ្រាន់សម្រាប់សន្និធិទំនិញនាំចេញ និងនាំចូល ។ គ្រោងឆ្អឹងអាគារនៃទីកន្លែងសន្និធិគយបណ្តោះអាសន្ន ត្រូវបង្កឲ្យមានភាពងាយស្រួលសម្រាប់ប្រតិបត្តិការ
- រដ្ឋបាលគយអាចគ្រប់គ្រង និងត្រួតពិនិត្យទម្រង់ការគយ លើទំនិញដែលសន្និធិក្នុងទីកន្លែងសន្និធិគយបណ្តោះអាសន្ន ដែលបានស្នើសុំ ។

៤. អាជ្ញាប័ណ្ណអាចត្រូវបានកែប្រែដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងគោលបំណង ៖

- ផ្លាស់ប្តូរនូវកម្រិតកំណត់ ឬលក្ខខណ្ឌនានាក្នុងអាជ្ញាប័ណ្ណពាក់ព័ន្ធនឹងទំនិញដែលអាចបញ្ចូលក្នុងទីកន្លែងសន្និធិគយបណ្តោះអាសន្ន ឬដើម្បីបញ្ជាក់បន្ថែមនូវកម្រិតកំណត់ និងលក្ខខណ្ឌនេះ

- ផ្លាស់ប្តូរនាមករណ៍របស់បុគ្គលទទួលអាជ្ញាប័ណ្ណប្រសិនបើនាមករណ៍នោះត្រូវបានផ្លាស់ប្តូរ ។

៥. អាជ្ញាប័ណ្ណអាចនឹងត្រូវបានលុបចោលដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រសិនបើបុគ្គលដែលទទួលបានអាជ្ញាប័ណ្ណ ៖

- លែងជាម្ចាស់ឬជាអ្នកជួលទីកន្លែងសន្និធិគយបណ្តោះអាសន្ន នោះ

- ស្នើសុំលុបអាជ្ញាប័ណ្ណជាលាយល័ក្ខអក្សរទៅរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- ត្រូវបានក្ស័យធន ។

៦. អាជ្ញាប័ណ្ណអាចនឹងត្រូវបានលុបចោលដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រសិនបើបុគ្គលដែលទទួលបានអាជ្ញាប័ណ្ណ ៖

- ជាកម្មវត្ថុនៃភាពដែលមិនអាចសងបំណុលរបស់ខ្លួនបាន

- ខកខាន មិនបានអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងការនាំចូល និងការនាំចេញទំនិញ

- បានប្រព្រឹត្តិអំពើមិនត្រឹមត្រូវ ក្នុងធុរកិច្ចរបស់ខ្លួន ជាមួយនឹង អាជ្ញាធរមានសមត្ថកិច្ច ជើងសារគយ អ្នកនាំចូល អ្នកនាំចេញ និងអ្នកដឹកជញ្ជូន

- គ្មានសមត្ថភាពដើម្បីធ្វើប្រតិបត្តិការទីកន្លែងសន្និធិគយបណ្តោះអាសន្ន ។

៧. បុគ្គលដែលទទួលបានអាជ្ញាប័ណ្ណប្រតិបត្តិការទីកន្លែងសន្និធិគយបណ្តោះអាសន្នត្រូវបង់កម្រៃអាជ្ញាប័ណ្ណប្រចាំឆ្នាំចំនួន ម្ភៃលាន (២០.០០០.០០០ ) រៀល ជូនទីចាត់ការគយ និងរដ្ឋាករដើម្បីបង់ចូលថវិការដ្ឋ ។

**ប្រការ ៣.-**

ប្រតិបត្តិករទីកន្លែងសន្និធិគយបណ្តោះអាសន្នត្រូវតែ [illegible] នា [illegible] ទីចាត់ការគយ និងរដ្ឋាករតាមចំនួនគ្រប់គ្រាន់សម្រាប់ធានា [illegible] ការបង់ពន្ធ [illegible] អាករ

កម្រៃ និងបន្ទុកផ្សេងៗលើទំនិញដែលផ្ទុកក្នុងទីកន្លែងសន្និធិគយបណ្តោះអាសន្ន ។ ទម្រង់នៃនិមុត្តិជានាត្រូវអនុលោមតាមបញ្ញត្តិមាត្រា ៤១ នៃច្បាប់ស្តីពីគយ និងបទបញ្ញត្តិពាក់ព័ន្ធ ។

**ប្រការ ៤.-**

រាល់ចំណាយពាក់ព័ន្ធទីកន្លែងសន្និធិគយបណ្តោះអាសន្ន រាប់បញ្ចូលទាំងថ្លៃថែទាំ និងជួសជុលជាបន្ទុករបស់ម្ចាស់កម្មសិទ្ធ ឬប្រតិបត្តិករ ។ ម្ចាស់កម្មសិទ្ធ ឬប្រតិបត្តិករទីកន្លែងសន្និធិគយបណ្តោះអាសន្ន ត្រូវជានាដោះស្រាយជូននូវទីកន្លែងសមរម្យ និងគ្រប់គ្រាន់ ដោយមិនយកកម្រៃជូនមន្ត្រីគយ ដើម្បីបំពេញការងារ ។

**ប្រការ ៥.-**

ប្រតិបត្តិករទីកន្លែងសន្និធិគយបណ្តោះអាសន្ន ជាអ្នកទទួលខុសត្រូវចំពោះពន្ធ អាករ និងកម្រៃផ្សេងៗ ដោយអនុលោមតាមបញ្ញត្តិមាត្រា ៣៩ នៃច្បាប់ស្តីពីគយ ។

ចំពោះទំនិញដែលខូច ឬដែលបាក់បែកដោយគ្រោះថ្នាក់ ឬករណីប្រធានស័ក្តិ ក្នុងរយៈពេលសន្និធិគយជាបណ្តោះអាសន្ន ដែលមន្ត្រីគយទទួលស្គាល់ នឹងត្រូវគិតពន្ធ និងអាករ លើមូលដ្ឋាននៃសភាពទំនិញនោះ នាពេលយកចេញពីទីកន្លែងសន្និធិគយបណ្តោះអាសន្ន ។

**ប្រការ ៦.-**

ទំនិញដែលដាក់ក្នុងទីកន្លែងសន្និធិគយបណ្តោះអាសន្ន ជាកម្មវត្ថុនៃការត្រួតពិនិត្យដោយគយ និងត្រូវសន្និធិ ដោយអនុលោមតាមនីតិវិធីដែលបានកំណត់។

ទំនិញត្រូវបានដាក់ក្នុងទីកន្លែងសន្និធិគយបណ្តោះអាសន្ន ក្នុងគោលបំណងផលដូចខាងក្រោម ៖

- រង់ចាំឯកសារចាំបាច់នានា សម្រាប់បំពេញទម្រង់ការគយ
- រង់ចាំផ្ទេរចេញ ឬបំបែកទំនិញចេញពីកុងតេន័រ

- សម្រាប់ត្រួតពិនិត្យទំនិញ
- រង់ចាំការបំពេញចម្ងងការពាណិជ្ជកម្ម ។

ទំនិញដែលដាក់ក្នុងទីកន្លែងសន្និធិគយបណ្តោះអាសន្ន ត្រូវបានបញ្ចេញពីគយជាបន្ទាន់ ក្រោយពេលដាក់ប្រតិវេទន៍គយដើម្បីបញ្ចេញទំនិញពីគយ ឬដើម្បីដឹកជញ្ជូនឆ្លងកាត់ និងក្រោយពេលបំពេញទម្រង់ការគយរួច ។

**ប្រការ ៧.-**

ការដាក់ទំនិញចូលទីកន្លែងសន្និធិគយបណ្តោះអាសន្ន ត្រូវបានផ្អាកនូវការបង់ពន្ធ អាករ និងកម្រៃនានា ព្រមទាំងតម្រូវការនៃការដាក់ប្រតិវេទន៍គយ និងឯកសារចាំបាច់នានា តាមនីតិវិធីបញ្ចេញទំនិញពីគយ ។

**ប្រការ ៨ .-**

ទំនិញទាំងឡាយអាចដាក់ចូលទីកន្លែងសន្និធិគយបណ្តោះអាសន្ន លើកលែងតែ ៖

- ទំនិញហាមឃាត់ដាច់ខាតដល់ការនាំចេញ និងនាំចូល
- ទំនិញដែលអាចបណ្តាលឲ្យមានគ្រោះថ្នាក់ដល់មនុស្ស និងដល់ទំនិញដទៃទៀត ឬដែលតម្រូវឲ្យមានទីកន្លែងសន្និធិដោយឡែក ដែលបំពាក់នូវបរិក្ខាពិសេស សម្រាប់សន្និធិទំនិញប្រភេទនេះ ។

**ប្រការ ៩.-**

ការដាក់ទំនិញចូលទីកន្លែងសន្និធិគយបណ្តោះអាសន្ន ត្រូវអនុវត្តតាមនីតិវិធីដូចតទៅ ៖

១. ទំនិញទាំងឡាយចាំបាច់ត្រូវបង្ហាញដល់មន្ត្រីគយ មុននឹងដាក់ទំនិញចូល ។

២.ត្រូវតម្កល់ប្រតិវេទន៍បំព្រួញដែលមានចុះហត្ថលេខាដោយប្រតិបត្តិករទីកន្លែងសន្និធិគយបណ្តោះអាសន្ន មុននឹងដាក់ទំនិញចូល ។

៣. ប្រតិវេទន៍បំពេញដែលនឹងកំណត់ដោយនាយកទីចាត់ការគយនិងរដ្ឋាករត្រូវមានចុះ៖

- លេខ និងកាលបរិច្ឆេទចុះបញ្ជិកា
- បរិមាណ ប្រភេទ សញ្ញា និងលេខកញ្ចប់
- បរិយាយមុខទំនិញ
- ទម្ងន់ទាំងសម្បក
- នាមរបស់អ្នកនាំចេញ ឬអ្នកនាំចូល
- ប្រទេសផ្គត់ផ្គង់ ឬនាំចេញ និងប្រទេសនាំចូល
- របៀប និងមធ្យោបាយដឹកជញ្ជូន
- ឯកសារយោងដែលចង្អុលបង្ហាញអំពី ប្រភេទ លេខ កាលបរិច្ឆេទ នៃឯកសារដឹកជញ្ជូននាពេលនាំចូល ឬឯកសារផ្សេងទៀតនាពេលនាំចេញ ។ ច្បាប់ចម្លងនៃឯកសារទាំងនេះត្រូវភ្ជាប់ជាមួយប្រតិវេទន៍បំពេញនៅពេលបង្ហាញជូនមន្ត្រីគយ ។

**ប្រការ ១០.-**

កិច្ចបញ្ជិកាប្រតិវេទន៍បំពេញ ត្រូវស្ថិតក្រោមលក្ខខណ្ឌដូចតទៅ៖

១. ប្រតិបត្តិករទីកន្លែងសន្និធិគយបណ្តោះអាសន្ន ត្រូវចុះបញ្ជីប្រតិវេទន៍បំពេញដែលមានចុះបញ្ជិកាគយរួចពីមន្ត្រីគយទៅក្នុងបញ្ជីសន្និធិគយបណ្តោះអាសន្ន នៅពេលដែលទំនិញត្រូវបានដាក់ក្នុងសន្និធិគយបណ្តោះអាសន្ន ។

២. បញ្ជីមួយត្រូវបានបង្កើតសម្រាប់ឃ្លាំងនីមួយៗ ឬទីលាននីមួយៗ នៃសន្និធិគយបណ្តោះអាសន្ន បញ្ជីនេះហៅថា បញ្ជីសន្និធិគយបណ្តោះអាសន្ន ។ បញ្ជីនេះត្រូវមានចុះសូចនាដូចមានចែងក្នុងបញ្ញត្តិកថាខ័ណ្ឌ ៣ ប្រការ ៩ នៃប្រកាសនេះ និងត្រូវចុះបញ្ជាក់ផងដែរនូវទីតាំងដោយឡែកនៃទំនិញទាំងឡាយក្នុងសន្និធិគយបណ្តោះអាសន្ន ។

៣.ទម្រង់នៃបញ្ជីសន្និធិគយបណ្តោះអាសន្ននឹងត្រូវកំណត់ដោយនាយកទីចាត់ការគយ និងរដ្ឋាករ ។

៤. បញ្ជីដាច់ដោយឡែកពីគ្នាត្រូវបានបង្កើតសម្រាប់ប្រតិបត្តិនាំចូល និងសម្រាប់ប្រតិបត្តិនាំចេញ ។

៥. លេខ និងកាលបរិច្ឆេទនៃការចុះបញ្ជិកាគយ ត្រូវធ្វើនៅលើឯកសារដែលភ្ជាប់នឹងប្រតិវេទន៍បំពេញ ។

៦. ក្រោយពេលបានបំពេញទម្រង់ការគយដូចរៀបរាប់ខាងលើរួចហើយ ទើបការត្រួតពិនិត្យបំពេញដោយគយរួមមាន ការរាប់ និងការផ្ទៀងផ្ទាត់អត្តសញ្ញាណនៃកញ្ចប់កាអាចត្រូវអនុវត្ត ។

**ប្រការ ១១.-**

នៅក្នុងទីកន្លែងសន្និធិគយបណ្តោះអាសន្ន ដោយមានការអនុញ្ញាតជាមុនពីគយ ប្រតិបត្តិករអាចធ្វើសហត្ថកម្មនានាលើទំនិញដូចខាងក្រោម ៖

- ការថ្លឹង ការពិនិត្យជាមុន និងការរៀបចំទុកដាក់តាមប្រភេទទំនិញ
- ការដកគម្រូទំនិញ
- ការពិនិត្យកត់ត្រា ពីការបែកបាក់ ការខូចខាត និងការជ្រើសរើសទំនិញខូចខាត
- ការជួសជុល ឬប្តូរសម្បកវេចខ្ចប់ក្នុងករណីចាំបាច់
- ការវេចខ្ចប់ជាថ្មី និងគ្រប់សហត្ថកម្មទាំងឡាយ សម្រាប់ធ្វើឲ្យទំនិញមានភាពល្អឡើងវិញ ដោយមិនប្តូរលក្ខណៈនៃទំនិញ
- ប្រតិបត្តិការទាំងឡាយក្នុងគោលបំណងថែរក្សាទំនិញ ដូចជា ការបោសសម្អាតធូលី ការជូតជាដើម
- ការបិទផ្លាក ឬសញ្ញាសម្គាល់ សម្រាប់គោលបំណង ដឹកជញ្ជូនទំនិញបន្តទៀត ។

**ប្រការ ១២.-**

កំណត់រយៈពេលសំចតនៃទំនិញក្នុងទីកន្លែងសន្និធិគយបណ្តោះអាសន្ន គិតពីថ្ងៃចុះបញ្ជិកាគយលើប្រតិវេទន៍បំពេញ ដូចតទៅ ៖

- សាមសិប (៣០) ថ្ងៃសម្រាប់ទីកន្លែងសន្និធិគយបណ្តោះអាសន្នតាមអាកាសយានដ្ឋាន

- សែសិបប្រាំ(៤៥) ថ្ងៃ សម្រាប់ទីកន្លែងសន្និធិគយបណ្តោះអាសន្នដែលមានទីតាំងស្ថិតនៅក្រៅអាកាសយានដ្ឋាន

រយៈពេលសំចតនេះ អាចត្រូវបានពន្យារពេលដោយ នាយកទីចាត់ការគយ និងរដ្ឋាករ សម្រាប់រយៈពេលមិនលើសពីរយៈពេលដូចមានចែងក្នុងវាក្យខណ្ឌខាងលើនៃប្រការនេះ ។

**ប្រការ ១៣.-**

ផុតរយៈពេលដូចបានកំណត់ក្នុងប្រការ ១២ ខាងលើ ទំនិញទាំងឡាយត្រូវបានដាក់ជាស្វ័យប្រវត្តិទៅក្នុងនិក្ខិត្តភ័ណ្ឌគយ កាលបើទំនិញទាំងនោះពុំបានធ្វើប្រតិវេទន៍គយ ។ ក្នុងរយៈពេលដែលទំនិញត្រូវបានដាក់ក្នុងនិក្ខិត្តភ័ណ្ឌគយម្ចាស់ទំនិញត្រូវបង់កម្រៃ ០,១០ ភាគរយ លើតម្លៃគិតពន្ធគយ ក្នុងមួយថ្ងៃ ជូនទីចាត់ការគយ និងរដ្ឋាករ ។ កម្រៃនេះ ត្រូវកត់ត្រាចូលក្នុងប្រតិវេទន៍គយ និងបង់ចូលថវិការដ្ឋ ។ ទំនិញទាំងឡាយដែលត្រូវតម្កល់ជានិក្ខិត្តភ័ណ្ឌគយត្រូវកត់ត្រាក្នុងបញ្ជីពិសេស ។

**ប្រការ ១៤.-**

ទំនិញទាំងឡាយ ដែលពុំបានបំពេញបែបបទបញ្ចេញទំនិញពីគយ ពីទីកន្លែងសន្និធិគយបណ្តោះអាសន្នក្នុងរយៈពេល បី ( ៣ ) ខែ គិតពីថ្ងៃកត់ត្រាចូលក្នុងបញ្ជីនៃនិក្ខិត្តភ័ណ្ឌគយ ត្រូវបានចាត់ទុកជាជា ទំនិញគ្មានការទាមទារ និងត្រូវបានដាក់ក្រោមបញ្ញត្តិមាត្រា ៥៤ និងមាត្រា ៥៥ នៃច្បាប់ស្តីពីគយ ។

ចំពោះទំនិញទាំងឡាយ ដែលឆាប់ខូច ឬលំបាករក្សាទុក អាចត្រូវបានលក់ជាបន្ទាន់ ដោយមានការអនុញ្ញាតជាមុន ពីនាយកទីចាត់ការគយ និងរដ្ឋាករ ។ ចំពោះទំនិញដែលមានតម្លៃតិចជាង ប្រាំរយពាន់ (៥០០,០០០) រៀល ត្រូវបានចាត់ទុកជា ម្ចាស់បានបោះបង់ចោល ហើយរដ្ឋបាលគយអាចបំផ្លាញចោល ឬធ្វើជាអំណោយដល់មន្ទីរពេទ្យ សង្គហដ្ឋាន ឬគ្រឹះស្ថានសប្បុរសធម៌ផ្សេងទៀត ។

**ប្រការ ១៥.-**

ទំនិញទាំងឡាយដែលបាននាំចូល មុនពេលដែលប្រកាសនេះចូលជាធរមាន ហើយកំពុងស្ថិតនៅក្នុងទឹកដែនសន្និធិគយបណ្តោះអាសន្ន ក៏ជាកម្មវត្ថុនៃការអនុវត្ត តាមបញ្ញត្តិនៃប្រកាសនេះដែរ ។

**ប្រការ១៦.-**

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ១៧ .-**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពនានា ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងបុគ្គល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**គាត ឈន់**

**ចម្លងជូន៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- ទីចាត់ការគយ និងរដ្ឋាករ
- ដូចប្រការ ១៧
- សភាពាណិជ្ជកម្មកម្ពុជា

"ដើម្បីសហការផ្សព្វផ្សាយ និងអនុវត្ត"

- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ